ក្រុមមេធាវី ខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# ការកែតម្រូវច្បាប់ហិរញ្ញវត្ថុ
# ឆ្នាំ ១៩៩៨

១៩៩៨

WWW.CAMLAW.COM.KH

រៀបចំភក្តីឡដ៍ PHEAKDEYLAW.COM.KH

# I.ខុទ្ទកាល័យព្រះមហាក្សត្រ

## ១ ព្រះរាជក្រម

## ព្រះរាជក្រមលេខ ០៨ នស ៩៤

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជាធិបតេយ្យ ឧភតោសុជាត ចិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់ទតព្រះរាជធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤-៩-១៩៩៣

- បានទ្រង់ទតព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១-១១-១៩៩៣

- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដូចមានសេចក្តីតទៅនេះ÷

## ភាគទីមួយ

## បទបញ្ញត្តិ នៃច្បាប់ហិរញ្ញវត្ថុកែតម្រូវ

**មាត្រា១.-**

មាត្រា១.២.៤.៦.២០ និង ៩៥ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានកែប្រែដូចតទៅ ÷

១ ថ្មី–

នៅតែត្រូវបានអនុញ្ញាតសម្រាប់ ឆ្នាំ ១៩៩៤ អោយប្រមូលចូលថវិកាទូទៅរបស់រដ្ឋ នូវពន្ធដា រ. ពករផលិតផល ផលទុន និង ចំណូលនានាព្រមទាំងធ្វើអោយសំរេចនូវអំណោយចូលនិធិបរិភាគ និងធនធានបានមកពីការខ្ចីបុលគ្រោងទុកនូវតារាង« ក »ក្នុងភាគទី២នៃច្បាប់នេះមានចំនួនទឹកប្រាក់សរុបដែលត្រូវបានរក្សាទុកជដែលស្មើនឹង ៨៨៩.៦០០ លានរៀល និង បែង ចែកឡើងវិញដូចតទៅ ÷

– ចំណូលជាប្រចាំ ៤៩៦.៧០០ លានរៀល

– ចំណូលជាមូលធន ៣៩២.៩០០ លានរៀល

មាត្រា២ ថ្មី–

ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានសម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសម្រាប់ឆ្នាំ ១៩៩៤ ត្រូវបានរក្សាទុកជដែលស្មើនឹង ៨៨៩.៦០០ លានរៀល និងបែងចែកឡើងវិញដូចតទៅ ÷

– ចំណាយជាប្រចាំ ៥៨៥.៦០០ លានរៀល

– ចំណាយជាមូលធន ៣០៤.០០០ លានរៀល

មាត្រា៤ ថ្មី–

ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានសម្រាប់ចំណាយជាប្រចាំរបស់រដ្ឋសម្រាប់ឆ្នាំ ១៩៩៤ ត្រូវបានកំណត់ស្មើនឹង ៥៨៥.៦០០ លានរៀល ។ ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនឹងក្រសួង និងតាមប្រភេទដូចមានចែងក្នុងតារាង«ខ»ភាគទី២នៃច្បាប់នេះ ។

មាត្រា៦ ថ្មី–

ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានស[illegible]ចំណាយជាមូលធននៃថវិការដ្ឋសម្រាប់ឆ្នាំ ១៩៩៤ ត្រូវបានកំណត់ស្មើនឹង ៣០៤.០០០ លានរៀល ។ ឥណទាននេះត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនឹងក្រសួង និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង « ឃ » ក្នុងភាគទី២ នៃច្បាប់នេះ ។

មាត្រា២០ ថ្មី–

ក្រៅពីរោងចក្រសហគ្រាសដែលស្ថិតនៅក្រោមអំណាចច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ ÷

– ២០ % ចំពោះប្រាក់ចំណេញដែលសំរេចបានដោយនីតិបុគ្គល

– តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ដូចមានចែងខាងក្រោមចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ១.០០០.០០០៛ | ១០% |
| ពី ១.០០០.០០១៛ ដល់ ១០.០០០.០០០៛ | ១៥% |
| ពី ១០.០០០.០០១៛ ដល់ ២០.០០០.០០០៛ | ២០% |
| លើសពី ២០.០០០.០០០៛ | ៣០% |

មាត្រា៩៩ ថ្មី–

ទោះក្នុងករណីណាក៏ដោយ ក្រុមរាជការគ្រឹះស្ថាន ឬអង្គការសាធារណៈទាំងឡាយ ព្រមទាំងសហគ្រាសរដ្ឋ សហសម្រាសចំរុះ សហគ្រាសដែលរដ្ឋអោយសម្បទាន ហើយនិងសហគ្រាសឯកជន ពុំអាចនឹងលាក់បាំងនូវការសម្ងាត់ក្នុងវិជ្ជាជីវៈចំពោះភ្នាក់ងារពន្ធដែលបំពេញមុខងារជាផ្លូវការរបស់ខ្លួន ហើយអោយលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ហើយដែលសាកសួរពត៌មាន និងឯកសារផ្សេងៗដែលទាក់ទងនឹងពន្ធដារ និង ពន្ធអាករ ដើម្បីនឹងកំណត់ពន្ធអាករ ឬប្រមូលពន្ធអាករ។

មាត្រា ២ :

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា

**ជា ស៊ីម**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិតិសម្បទា
និងរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
និង ហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ហត្ថលេខា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**